# ច្បាប់ថ្មីដាក់គោលដៅដល់និយោជកមិនស្មោះត្រង់ទាំងឡាយ

ច្បាប់ថ្មីនេះនឹងការពារជនអន្តោប្រវេសន៍ពីការកេងប្រវ័ញ្ចកន្លែងការងារដោយការដាក់ទណ្ឌកម្មធ្ងន់ធ្ងរចំពោះការប្រើលក្ខខណ្ឌទិដ្ឋាការមិនត្រឹមត្រូវដើម្បីកេងប្រវ័ញ្ចបុគ្គលិកអន្តោប្រវេសន៍កាន់ទិដ្ឋាការបណ្តោះអាសន្ន។

វិធានទាំងឡាយក្រោមច្បាប់ស្តីពីការពង្រឹងការគោរពតាមច្បាប់របស់និយោជកនឹងរារាំងដល់និយោជកមិនស្មោះត្រង់ពីការប្រើប្រាស់លក្ខខណ្ឌទិដ្ឋាការបុគ្គលណាម្នាក់ ឬស្ថានភាពអន្តោប្រវេសន៍ខុសច្បាប់របស់គេ ដើម្បីកេងប្រវ័ញ្ចពួកគេនៅកន្លែងការងារ។ ការដាក់ទោសព្រហ្មទណ្ឌរួមមានការជាប់ពន្ធនាគារ 2ឆ្នាំ និង/ឬពិន័យ 360 ឯកតាពិន័យ (បច្ចុប្បន្ននេះស្មើនឹង $118,800)។ ការបង់ពិន័យស៊ីវិលស្មើនឹង 240 ឯកតាពិន័យ (បច្ចុប្បន្ននេះស្មើនឹង$79,200)។

វិធានការផ្សេងៗដែលនឹងចាប់ផ្តើមនៅថ្ងៃទី 01 កក្កដា 2024 គ្របដណ្តប់ទាំងរឿងរ៉ាវផ្សេងៗពាក់ព័ន្ធ និងមិនពាក់ព័ន្ធនឹងការងារដែលកើតមានឡើងនៅកន្លែងបំពេញការងារ។ នេះរួមមានស្ថានភាពដែលបុគ្គលិកត្រូវបានដាក់សម្ពាធឲ្យប្រគល់លិខិតឆ្លងដែន ទទួលយកការរស់នៅក្នុងផ្ទះមិនសមស្រប ចូលរួមនៅក្នុងសកម្មភាពផ្លូវភេទមិនចង់បាន ឬការបំពានការដាក់កំហិតនៅក្នុងទិដ្ឋាការ។ វិធានការថ្មីៗក៏នឹងអនុវត្តនៅក្នុងស្ថានភាពទាំងឡាយដែលបុគ្គលិកអន្តោប្រវេសន៍ទទួលបានប្រាក់ខែទាបជាងប្រាក់ខែអប្បរមា ឬនិយោជករបស់គេគំរាមលុបទិដ្ឋាការ (និយោជកមិនអាចលុបទិដ្ឋាការបានទេ)។

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនពីអាកប្បកិរិយានៅក្នុងចង្វាក់ការងារដែលកេងប្រវ័ញ្ចជនអន្តោប្រវេសន៍ និងរំលោភច្បាប់។

សិទ្ធិបុគ្គលិកអន្តោប្រវេសន៍

ច្បាប់កេងប្រវ័ញ្ចបុគ្គលិកអន្តោប្រវេសន៍ថ្មី

| និយោជកបង្ខំជនអន្តោប្រវេសន៍ឲ្យរំលោភលើលក្ខខណ្ឌទិដ្ឋាការរបស់គេ | ក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិកកេងប្រវ័ញ្ចជនអន្តោប្រវេសន៍គ្មានឯកសារ | និយោជកប្រើប្រាស់ឋានៈទិដ្ឋាការបណ្តោះអាសន្នដើម្បីកេងប្រវ័ញ្ច |
|---|---|---|
| ច្បាប់ថ្មីនេះដាក់គោលដៅលើនិយោជក និងភាគីផ្គត់ផ្គង់ទីបីទាំងឡាយដែលដាក់សម្ពាធអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នឲ្យរំលោភលក្ខខណ្ឌទិដ្ឋាការការងារ។<br><br>ករណីសិក្សា<br><br>Chen ជាសិស្សអន្តរជាតិនៅសាកលវិទ្យាល័យអូស្ត្រាលីមួយ និងបំពេញការងារនៅស្ថានីយ៍ចាក់សាំង។ Chen ទទួលធ្វើការងារនៅចុងសប្តាហ៍ដើម្បីជួយដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ។<br><br>ប៉ុន្តែការងារបន្ថែមរបស់គាត់បំពេញរហូតដល់លើស 48 ម៉ោងដែលបានអនុញ្ញាតដោយទិដ្ឋាការសិស្សរបស់គាត់។ ប្រធានរបស់ Chen ដឹងពីលក្ខខណ្ឌនេះ ប៉ុន្តែនៅតែដាក់ម៉ោងឲ្យធ្វើការបន្ថែម។ ប្រធានរបស់ Chen ក៏បង់ប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បរមាផងដែរ។<br><br>Chen បានពិភាក្សាពីការបង់ប្រាក់ឈ្នួលទាបជាមួយថៅកែរបស់គាត់។ ថៅកែប្រាប់ Chen ថា ប្រសិនបើមិននៅស្ងៀមទេ គាត់នឹងរាយការណ៍ករណី Chen ទៅអាជ្ញាធរដែលធ្វើការលើសម៉ោងអនុញ្ញាត ហើយទិដ្ឋាការរបស់ Chen អាចត្រូវលុបចោល។ វាជាអំពើខុសច្បាប់រួចទៅហើយក្នុងការបង់ប្រាក់ឈ្នួលដល់នរណាម្នាក់ទាបជាងប្រាក់ឈ្នួលអប្បបរមា និងការអនុញ្ញាតឲ្យធ្វើការរំលោភលើលក្ខខណ្ឌទិដ្ឋាការរបស់គេ។ ក្រោមវិធានការណ៍ថ្មីៗទាំងនេះ ក៏នឹងបង្កឲ្យមានបទល្មើសថ្មីៗផងដែរ។ | ច្បាប់ថ្មីមួយដាក់គោលដៅលើនិយោជក និងជនទីបីទាំងឡាយណាដែលដាក់សម្ពាធអ្នកគ្មានទិដ្ឋាការមានសុពលភាពឲ្យទទួលយកការចាត់ចែងការងារ។<br><br>ករណីសិក្សា<br><br>123 គឺជាក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិក ដែលផ្គត់ផ្គង់កម្មករដល់អាជីវកម្មកសិកម្មនៅទូទាំងអូស្ត្រាលី។ Sally ដែលទិដ្ឋាការទេសចរណ៍របស់នាងបានផុតកំណត់ គឺជាកម្មករមួយរូប។ ក្រុមហ៊ុនដឹងថា Sally រស់នៅប្រទេសអូស្ត្រាលីដោយគ្មានទិដ្ឋាការមានសុពលភាព ប៉ុន្តែនៅតែបញ្ជូននាងទៅធ្វើការ។<br><br>ក្រោយមក Sally ដឹងថានាងទទួលបានប្រាក់ឈ្នួលទាបជាងបុគ្គលិកផ្សេងទៀតបំពេញការងារជាមួយ ហើយនាងបានប្តឹង។ ក្រុមហ៊ុនបានប្រាប់នាងថានាងគ្មានសិទ្ធិធ្វើការទេ ហើយគំរាមរាយការណ៍នាងទៅអាជ្ញាធរប្រសិនបើនាងប្តឹង។<br><br>ក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិកបានរំលោភច្បាប់រួចទៅហើយក្នុងការអនុញ្ញាត Sally ឲ្យធ្វើការដោយគ្មានទិដ្ឋាការមានសុពលភាព និងបង់ប្រាក់ឈ្នួលទាបដល់នាង។ ក្រោមបទល្មើសថ្មី ក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិកអាចរងនូវការចោទប្រកាន់ឧក្រិដ្ឋបន្ថែមទៀត។ | ច្បាប់ថ្មីមួយដាក់គោលដៅដល់និយោជក និងអ្នកផ្គត់ផ្គង់ភាគីទីបីទាំងឡាយណាដែលដាក់សម្ពាធអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នឲ្យទទួលយក ឬយល់ព្រមនឹងការចាត់ចែងការងារ - និយាយរួមគឺប្រើប្រាស់ឋានៈទិដ្ឋាការបណ្តោះអាសន្នរបស់គេ (ឬសេចក្តីប្រាថ្នាក់ដាក់ពាក្យសុំទិដ្ឋាការពេលអនាគត) ដើម្បីកេងប្រវ័ញ្ចពួកគេ។<br><br>ករណីសិក្សា<br><br>Nitia ជាបុគ្គលិកផ្នែក IT ដែលត្រូវបានធានាឲ្យមកធ្វើការនៅអូស្ត្រាលី។ នាងរំភើបចិត្តណាស់ដែលនាងអាចនឹងទទួលបានការរស់នៅអចិន្ត្រៃយ៍នៅអូស្ត្រាលីពេលអនាគត។ បន្ទាប់ពីនាងចាប់ផ្តើមការងារថ្មីរបស់នាងភ្លាម ប្រធានរបស់នាងបាននិយាយរឿងរ៉ាវផ្លូវភេទមិនសមស្របលើនាង និងធ្វើការប៉ះពាល់ខ្លួនប្រាណដែលនាងមិនត្រូវការ ពេលគាត់និយាយជាមួយ Nitia។<br>ពេល Nitia រាយការណ៍ពីបញ្ហានេះឲ្យមានការយកចិត្តទុកដាក់ពីថៅកែរបស់នាង គាត់បាននិយាយថាប្រសិនបើនាងបង្កបញ្ហា នាងនឹងគ្មានឱកាសទទួលបានការធានាដើម្បីសុំទិដ្ឋាការអចិន្ត្រៃយ៍នោះទេ។ ការបៀតបៀនកេរ្តិ៍ខ្មាសគឺជាអំពើផ្ទុយពីច្បាប់ ហើយក្រោមបទល្មើសថ្មី ថៅកែរបស់ Nitia អាចរងការចោទប្រកាន់បទឧក្រិដ្ឋថ្មីដែលប្រើឋានៈទិដ្ឋាការរបស់ Nitia ដើម្បីរំលោភបំពានលើនាង។ |